**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**លេខ** :............០.៧២/២០.............**ក.ប/ប្រ.ក.ខ.ល**

# ប្រកាសអន្តរក្រសួង
# ស្តីពី
# ការបង្កើតក្រុមអធិការកិច្ចអន្តរក្រសួងក្នុងវិស័យឧស្សាហកម្មទេសចរណ៍

**រដ្ឋមន្ត្រី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** **រដ្ឋមន្ត្រី ក្រសួងបរិស្ថាន** **រដ្ឋមន្ត្រី ក្រសួងទេសចរណ៍**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ២៨៣អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ១៣៥អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ២៥៨អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- យោងលិខិតលេខ ៥៣៤ សជណ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩ ស្តីពីលទ្ធផលនៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី១៨ របស់ទីស្តីការគណៈរដ្ឋមន្ត្រី


អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតក្រុមអធិការកិច្ចអន្តរក្រសួង នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងទេសចរណ៍ និងក្រសួងបរិស្ថាន។

ការបង្កើតក្រុមអធិការកិច្ចអន្តរក្រសួងនេះ មានគោលបំណងចុះធ្វើអធិការកិច្ចរួមគ្នាក្នុងពេលតែមួយ ដើម្បីត្រួតពិនិត្យការអនុវត្តរបស់សហគ្រាស គ្រឹះស្ថាន នូវបទប្បញ្ញត្តិ និងលិខិតបទដ្ឋានពាក់ព័ន្ធនឹងវិស័យការងារ វិស័យឧស្សាហកម្មទេសចរណ៍ និងវិស័យបរិស្ថាន។

**ប្រការ២ .-**

និយោជកនៃសហគ្រាស គ្រឹះស្ថាន ដែលស្ថិតក្រោមដែនអនុវត្តន៍ច្បាប់ដែលពាក់ព័ន្ធនឹងវិស័យការងារ វិស័យឧស្សាហកម្មទេសចរណ៍ និងវិស័យបរិស្ថាន ត្រូវអនុវត្តការបំពេញបែបបទ និងលក្ខខណ្ឌការងារ ដែលច្បាប់បានកំណត់ និងត្រូវបង្កលក្ខណៈងាយស្រួលដល់ក្រុមអធិការកិច្ចអន្តរក្រសួង ដើម្បីធ្វើការត្រួតពិនិត្យ។

**ប្រការ៣ .-**

ក្រុមអធិការកិច្ចអន្តរក្រសួង ត្រូវមានលិខិតបង្គាប់ការរួម ដែលចេញរួមគ្នាដោយរដ្ឋមន្ត្រីក្រសួងទាំង៣ និងមានភារកិច្ចធ្វើអធិការកិច្ចនៅក្នុងសហគ្រាស គ្រឹះស្ថាន ស្ថិតក្រោមដែនអនុវត្តន៍ និងការគ្រប់គ្រងដោយក្រសួងទាំង៣។

**ប្រការ៤ .-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរពិសោធន៍ ប្រធានមន្ទីររាជធានី ខេត្ត នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងទេសចរណ៍ និងក្រសួងបរិស្ថាន ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៥កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០

| រដ្ឋមន្ត្រី | រដ្ឋមន្ត្រី | រដ្ឋមន្ត្រី |
|---|---|---|
| ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ក្រសួងបរិស្ថាន | ក្រសួងទេសចរណ៍ |
| អ៊ិត សំហេង | សាយ សំអាល់ | ថោង ខុន |

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ

  *"ដើម្បីជូនជ្រាប"*
- ដូចប្រការ៤

  *"ដើម្បីអនុវត្ត"*
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ